**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**
លេខៈ ១១១៨ សាង.សប.ស្ក

# សេចក្តីថ្លែងហេតុ
# ស្តីពី
# ការស្នើសុំផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ

ជាបឋមខ្ញុំបាទ

- *សូមគោរព* ***សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា*** *ជាទីគោរពដ៏ខ្ពង់ខ្ពស់!*
- *សូមគោរព សម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ជាទីគោរព!*
- *ឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិក សមាជិកា នៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ជាទីគោរពរាប់អាន!*

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនចំពោះ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានអនុញ្ញាតឱ្យក្រសួងបរិស្ថានដាក់សំណើសុំផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្តីពីការប្រែប្រួលអាកាសធាតុ ទៅក្នុងរបៀបវារៈនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនាថ្ងៃនេះ ដើម្បីសុំការពិនិត្យ និងអនុម័តដ៏ខ្ពង់ខ្ពស់។

ខ្ញុំបាទសូមគោរពជម្រាបជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** និងអង្គប្រជុំទាំងមូលមេត្តាជ្រាបថា ក្នុងនាមជាស្ថាប័នបង្គោលនៃអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ក្រសួងបរិស្ថាន បានរៀបចំឯកសារសម្រាប់ព្រះរាជាណាចក្រកម្ពុជាផ្តល់សច្ចាប័នដល់កិច្ចព្រមព្រៀងនេះ ដោយអនុលោមតាមនីតិវិធីច្បាប់ដែលមានជាធរមាន។

ខ្ញុំបាទសុំការអនុញ្ញាតពី **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដើម្បីជម្រាបជូនអង្គប្រជុំអំពីប្រវត្តិសង្ខេប និងអត្ថប្រយោជន៍ នៃកិច្ចព្រមព្រៀងស្តីពីការប្រែប្រួលអាកាសធាតុ ដែលមានខ្លឹមសារដូចខាងក្រោម៖

អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ដែលបានអនុម័តក្នុងកិច្ចប្រជុំកំពូលស្តីពីភពផែនដី នៅទីក្រុងរីយ៉ូ ប្រទេសប្រេស៊ីល ឆ្នាំ១៩៩២ បានចូលជាធរមាននៅឆ្នាំ១៩៩៤។ គោលបំណងចម្បងនៃអនុសញ្ញានេះ គឺដើម្បីរក្សាស្ថិរភាពកំហាប់ឧស្ម័នផ្ទះកញ្ចក់ (GHG) នៅក្នុងបរិយាកាស ក្នុងកម្រិតមួយដែលអាចការពារប្រព័ន្ធអាកាសធាតុទប់ទល់នឹងការរំខានប្រកបដោយគ្រោះថ្នាក់ដែលបង្កឡើងដោយសកម្មភាពមនុស្ស។ ប្រទេសចំនួន១៩៧ រួមទាំងព្រះរាជាណាចក្រកម្ពុជា បានផ្តល់សច្ចាប័នលើអនុសញ្ញានេះ ហើយព្រះរាជាណាចក្រកម្ពុជាក៏បានចុះហត្ថលេខាលើលិខិតូបករណ៍


អគារមរតកតេជោ ដីឡូលេខ503 ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទៈ ០២៣ ២១៣ ៩០៨, ០២៣ ២២០ ៣៦៩ ទូរសារៈ ០២៣ ២១២ ៥៤០

នៃពិធីសារក្យូតូដែលបានអនុម័តនៅក្នុងសន្និសីទបណ្តាភាគីលើកទី៣ (COP3) ឆ្នាំ១៩៩៧ នៅប្រទេសជប៉ុនផងដែរ។ សន្និសីទ ប្រចាំឆ្នាំនៃបណ្តាភាគីអនុសញ្ញា UNFCCC លើកទី២១ (CoP21) នៅទីក្រុងប៉ារីស កាលពីចុងឆ្នាំ២០១៥ បានអនុម័តកិច្ចព្រមព្រៀងជាប្រវត្តិសាស្ត្រ ហៅថា **កិច្ចព្រមព្រៀងទីក្រុងប៉ារីស** ដើម្បីដោះស្រាយការការប្រែប្រួលអាកាសធាតុ ជាពិសេស ដើម្បីជំរុញការវិនិយោគដែលបញ្ចេញកាបូនទាបប្រកបដោយចីរភាពនៅពេលអនាគត។ កិច្ចព្រមព្រៀងទីក្រុងប៉ារីសនេះ បានបន្ថែមទៅលើកាតព្វកិច្ចដែលមានចែងនៅក្នុងអនុសញ្ញា UNFCCC ដែលជំរុញឱ្យភាគីទាំងអស់ខិតខំប្រឹងប្រែងអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្នុងការដោះស្រាយការប្រែប្រួលអាកាសធាតុ និងបន្សាំទៅនឹងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ។ កិច្ចព្រមព្រៀងទីក្រុងប៉ារីស មានគោលបំណងដើម្បីពង្រឹងការឆ្លើយតបជាសកលទៅនឹងការគំរាមកំហែងនៃការប្រែប្រួលអាកាសធាតុ នៅក្នុងបរិបទនៃការអភិវឌ្ឍដោយចីរភាព និងកិច្ចខិតខំប្រឹងប្រែងដើម្បីលុបបំបាត់ភាពក្រីក្រដែលរួមមាន៖ (១) ការកំហិតកំណើនសីតុណ្ហភាពមធ្យមពិភពលោកឱ្យនៅត្រឹមក្រោម២អង្សាសេ ធៀបនឹងកម្រិតសីតុណ្ហភាពមុនបដិវត្តន៍ឧស្សាហកម្ម និងបន្តការខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីកំហិតកំណើន សីតុណ្ហភាពឱ្យនៅត្រឹម១,៥អង្សាសេ (២) ការបង្កើនសមត្ថភាព ដើម្បីបន្សាំ និងពង្រឹងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងជំរុញការអភិវឌ្ឍបញ្ចេញកាបូនទាប ដែលមិនបង្កការគំរាមកំហែងចំពោះផលិតកម្មស្បៀង និង(៣) ធ្វើឱ្យមានលំហូរហិរញ្ញវត្ថុប្រកបដោយសង្គតិភាពជាមួយដំណើរការអភិវឌ្ឍដែលធន់នឹងអាកាសធាតុ និងបញ្ចេញឧស្ម័នផ្ទះកញ្ចក់កម្រិតទាប។ ការអនុវត្តកិច្ចព្រមព្រៀងទីក្រុងប៉ារីស គឺពឹងផ្អែកលើគោលការណ៍ចម្បងរបស់អនុសញ្ញាគឺ **«ទទួលខុសត្រូវរួម តែក្នុងកម្រិតខុសៗគ្នានិងអនុលោមទៅតាមសមត្ថភាព និងស្ថានភាពជាក់ស្តែងរៀងៗខ្លួនរបស់ភាគី»**។

ជាមួយគ្នានេះ រដ្ឋភាគីនីមួយៗត្រូវរៀបចំ «របាយការណ៍ស្តីពីឆន្ទៈរបស់ខ្លួនក្នុងការចូលរួមចំណែកអនុវត្តអនុសញ្ញា (Intended Nationally Determined Constribution: INDC)» ដើម្បីដាក់ជូនលេខាធិការដ្ឋាន UNFCCC ដែលរបាយការណ៍នេះនឹងក្លាយទៅជា «ផែនការស្តីពីការចូលរួមចំណែករបស់រដ្ឋភាគីក្នុងការអនុវត្តអនុសញ្ញា (Nationally Determined Constribution: NDC)» នៅពេលដែលរដ្ឋភាគីនោះបានផ្តល់សច្ចាប័នដល់កិច្ចព្រមព្រៀងនេះ។ ព្រះរាជាណាចក្រកម្ពុជាបានដាក់ «របាយការណ៍ស្តីពីឆន្ទៈកម្ពុជាក្នុងការចូលរួមចំណែកអនុវត្តអនុសញ្ញា» របស់ខ្លួនទៅលេខាធិការដ្ឋានអនុសញ្ញា UNFCCC នៅមុនសន្និសីទប្រចាំឆ្នាំលើកទី២១ នៅទីក្រុងប៉ារីស។ របាយការណ៍នេះ បានបញ្ជាក់ថា ក្នុងករណីមានជំនួយហិរញ្ញវត្ថុ និងបច្ចេកវិទ្យា កម្ពុជានឹងចូលរួមជាមួយសហគមន៍អន្តរជាតិក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីបរិមាណ ១១៦០០ ពាន់តោន គិតជាសមមូលឧស្ម័នកាបូនិក មកនៅត្រឹមបរិមាណ ៣១០០ ពាន់តោន នៅឆ្នាំ២០៣០ ពីវិស័យថាមពល និងដឹកជញ្ជូន។ ទន្ទឹមនឹងនេះប្រសិនបើប្រទេសកម្ពុជាអាចរក្សាគម្របព្រៃឈើឱ្យបាននៅ៦០% នោះកម្ពុជាអាចរក្សាសមត្ថភាពស្រូបយកកាបូនបានប្រមាណ ១៨៤៩២ ពាន់តោន គិតជាសមមូលឧស្ម័នកាបូនិក។ ទោះជាយ៉ាងណា «ផែនការស្តីពីការចូលរួមចំណែករបស់រដ្ឋភាគីក្នុងការអនុវត្តអនុសញ្ញា» ត្រូវការកែសម្រួលឡើងវិញ ដើម្បីឱ្យស្របទៅតាមគោលនយោបាយ និងផែនការការអភិវឌ្ឍរបស់ជាតិ។

ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **សម្តេចតេជោនាយករដ្ឋមន្ត្រី** ព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ កាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ

២០១៦ នៅទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក។ រហូតមកដល់ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៦ នេះ មានប្រទេសចំនួន២៩ បានផ្តល់សច្ចាប័ន លើកិច្ចព្រមព្រៀងទីក្រុងប៉ារីស។

កិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្តីពីការប្រែប្រួលអាកាសធាតុ រួមមាន ២៩មាត្រា ហើយមាត្រាសំខាន់ៗរបស់កិច្ចព្រមព្រៀងនេះ សមស្របទៅនឹងគោលជំហររបស់កម្ពុជា ជាអាទិ៍៖

- ជំរុញការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក្នុងបរិបទនៃការអភិវឌ្ឍដោយចីរភាព និងកិច្ចប្រឹងប្រែងដើម្បីកាត់បន្ថយភាពក្រីក្រ និងការប្រកាន់យកគោលការណ៍នៃការទទួលខុសត្រូវរួម តែក្នុងកម្រិតខុសៗគ្នានិងអនុលោមទៅតាមសមត្ថភាពនិងស្ថានភាពជាក់ស្តែងរៀងៗខ្លួន
- កំណត់គោលដៅរយៈពេលវែងនៃការទប់ស្កាត់កំណើនសីតុណ្ហភាពពិភពលោកនៅក្នុងសតវត្សរ៍នេះឱ្យស្ថិតនៅទាបជាង២អង្សាសេ
- ការប្តេជ្ញាចិត្តកាត់បន្ថយឧស្ម័នដែលជាកាតព្វកិច្ចសម្រាប់គ្រប់ភាគី តាមរយៈការដាក់ជូន «ផែនការស្តីពីការចូលរួមចំណែករបស់រដ្ឋភាគីក្នុងការអនុវត្តអនុសញ្ញា» ដែលក្នុងនោះ ប្រទេសឧស្សាហកម្មជឿនលឿនត្រូវតែបន្តនាំមុខក្នុងការអនុវត្តចំណុចដៅនៃការកាត់បន្ថយជាក់ស្តែង។ ទន្ទឹមនឹងនេះ ប្រទេសកំពុងអភិវឌ្ឍន៍ «ត្រូវបានលើកទឹកចិត្ត» ចូលរួមក្នុងបរិបទនៃការគាំទ្ររបស់ប្រទេសឧស្សាហកម្មជឿនលឿន និងស្ថានភាពរបស់ខ្លួន
- ផ្តល់ការគាំទ្រដល់សកម្មភាពកាត់បន្ថយ និងបន្សាំសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសប្រទេសងាយរងគ្រោះខ្លាំង និងប្រទេសដែលមានការអភិវឌ្ឍតិចតួច ក្នុងការឆ្លើយតបនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ
- កិច្ចព្រមព្រៀងនេះក៏មានដាក់បញ្ចូលការខូចខាត និងការបាត់បង់ បណ្តាលមកពីការប្រែប្រួលអាកាសធាតុ
- រៀបចំយន្តការកំណត់ថ្លៃកាបូនជាថ្មី ដើម្បីរួមចំណែកកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព ព្រមទាំងកាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់ និងការរេចរឹលព្រៃឈើ និងពង្រឹងតួនាទីនៃការគ្រប់គ្រង និងការអភិរក្សព្រៃឈើដោយនិរន្តរភាព និងការពង្រីកអាងស្តុកកាបូនព្រៃឈើ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។

ខ្ញុំបាទសូមគោរពជម្រាបជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** និងអង្គប្រជុំទាំងមូល មេត្តាជ្រាបថាការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងនេះ កម្ពុជានឹងទទួលអត្ថប្រយោជន៍សំខាន់ៗ ដូចជា៖

- សហគមន៍អន្តរជាតិទទួលស្គាល់ឆន្ទៈនយោបាយ ការប្តេជ្ញាចិត្ត និងកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការចូលរួមដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ
- ជំរុញឱ្យប្រទេសមានឧស្សាហម្មជឿនលឿននាំមុខក្នុងការអនុវត្តកាតព្វកិច្ចតាមផ្លូវច្បាប់ និងមានការទទួលខុសត្រូវចំពោះការប្តេជ្ញារបស់ខ្លួន
- កម្ពុជាអាចនឹងទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុ ការផ្ទេរបច្ចេកវិទ្យា និងការកសាងសមត្ថភាពបន្ថែម ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ ជាពិសេសស គឺការអនុវត្តសកម្មភាពលើកកម្ពស់ប្រសិទ្ធភាពថាមពល និងថាមពលកកើតឡើងវិញ ការការពារព្រៃឈើ

ការកែលំអហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ដែលធន់នឹងអាកាសធាតុ ដូចមានចែងនៅក្នុង «ផែនការស្តីពីការចូលរួមចំណែករបស់រដ្ឋភាគីក្នុងការអនុវត្តអនុសញ្ញា» ។

ជាមួយគ្នានេះដែរ នៅក្នុងកិច្ចព្រមព្រៀងនេះ កម្ពុជានឹងមានកាតព្វកិច្ចដូចបណ្តាប្រទេសអភិវឌ្ឍន៍តិចតួច និងប្រទេសកំពុងអភិវឌ្ឍដទៃទៀត ក្នុងការចូលរួមអនុវត្ត «ផែនការស្តីពីការចូលរួមចំណែករបស់រដ្ឋភាគីក្នុងការអនុវត្តអនុសញ្ញា» របស់ខ្លួន។ ក៏ប៉ុន្តែ ការអនុវត្តផែនការរបស់កម្ពុជានេះ គឺអាស្រ័យដោយមានការគាំទ្រពីបណ្តាប្រទេសឧស្សាហកម្មជឿនលឿន ពោលគឺអនុលោមតាមគោលការណ៍ចម្បងរបស់អនុសញ្ញា។

សេចក្តីដូចបានជម្រាបជូនខាងលើសូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី មេត្តាពិនិត្យ និងអនុម័តលើការស្នើសុំផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្តីពីការប្រែប្រួលអាកាសធាតុនេះ ដោយក្តីអនុគ្រោះ។

*សូមអរគុណ!*

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែ កញ្ញា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**និងជាប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព**

សាយ សំអាល់